# ពើងតាបស ភ្នំត្បែង

ពើងតាបស ស្ថិតនៅលើភ្នំត្បែង ក្នុងភូមិសាស្រ្ត ភូមិសម្ញាញ ឃុំត្បែង១ ស្រុកសង្គមថ្មី ខេត្តព្រះវិហារ ដែលមានចំណុចនិយាមការ X 486389 Y 1511175 កម្ពស់៤៦៨ម៉ែត្រធៀបនឹងទឹកសមុទ្រ។ សូមបញ្ជាក់ថាភ្នំត្បែងត្រូវបានរាជរដ្ឋាភិបាលដាក់បញ្ចូលជាតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង ដោយអនុក្រឹត្យលេខ ១៨៩ អនក្រ.បក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ ២០១៦ ដែលមានផ្ទៃដី ២៥២៦៩,២១ ហិកតា។[១]

យើងអាចធ្វើដំណើរពីទីតាំងវត្តថ្មបីដុំឆ្ពោះទៅកាន់ពើងតាបសដោយថ្មើរជើង ឬម៉ូតូ ដែលមានចំងាយប្រមាណ៥គីឡូម៉ែត្រ (រូបលេខ១)។ ពើងតាបសស្ថិតនៅចម្រាក់ភ្នំមានពើងថ្ម៤ដុំធំៗ មានបណ្តោយ១៥.៤០ម៉ែត្រ កម្ពស់៣.៤៥ម៉ែត្រ ដែលជាគុហានៃក្រុមអ្នកបួសសម្រាប់ធ្វើពិធីសមណធម៌នៅទីនោះ (រូបលេខ២)។ ក្នុងពើងតាបសមានរូងថ្មតូចៗចំនួន៣ដែលកើតឡើងដោយការគងគ្នានៃផ្ទាំងថ្មធំៗ និងមានចម្លាក់មួយចំនួនលើផ្ទៃជញ្ជាំងរូងថ្មទី១ និងរូងថ្មទី២។ នៅលើផ្ទៃជញ្ជាំងនៃពើងតាបសឃើញមានសិលាចារឹកចំនួន២កន្លែង និងឃើញមានចម្លាក់មួយចំនួន។ ចម្លាក់ព្រះពុទ្ធប្រក់នាគក្នុងរូងថ្មទី១ មានភ្នែនប្រវែង៦៥សង់ទីម៉ែត្រ កម្ពស់៨៥សង់ទីម៉ែត្រ មានក្បាល៧ ព្រះពុទ្ធសម្មាធិ មានទ្រង់គ្រឿងអលង្ការក្រវិល ខ្សែក និងអាចមានមកុដ ចម្លាក់នេះឆ្លាក់មិនទាន់រួចរាល់នៅឡើយទេ (រូបលេខ៣-៤)។ រីឯចម្លាក់ព្រះពុទ្ធរូបជាក្រុម (រូបលេខ៥) (ជារូបព្រះពោធិសត្វអវលោកេស្វរៈ និងពោធិសត្វប្រាជ្ញាបារមីតា) ចម្លាក់ព្រះពោធិសត្វអវលោកេស្វរៈ និងទេពមួយអង្គ តែត្រូវបែកចេញដែលបំណែកនេះឃើញនៅក្បែរនោះដែរ ជិតចម្លាក់ព្រះពោធិសត្វអវលោកេស្វរៈ(រូបលេខ៦) និងចម្លាក់ព្រះពោធិសត្វពីរអង្គឆ្លាក់ជាមួយគ្នា រូបទេពព្រះហស្ត៨ជាព្រះពោធិសត្វអវលោកេស្វរៈ ដោយព្រះហស្តទាំង៤ផ្នែកខាងឆ្វេង មួយកាន់ថូទឹក និង៣ទៀតមិនច្បាស់ រីឯព្រះហស្តទាំង៤ផ្នែកខាងស្តាំ មួយកាន់ផ្កាឈូក និង៣ទៀតមិនច្បាស់ រូបនេះមានកម្ពស់១០៨ស.ម និងទទឹង៦២ស.ម(រូបលេខ៧)។ នៅខាងស្តាំនៃចម្លាក់មានចម្លាក់ទេពមួយអង្គទៀតមិនដឹងជាទេពអ្វី? ដៃខាងឆ្វេងរូបដាក់លើទ្រូង មានកម្ពស់៨៣ស.ម និងទទឹង៣០ស.ម។

---

[១]អនុក្រឹត្យ ១៨៩អនក្រ.បក: ២០១៦

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ

ឃ្លាតបន្តិចមកខាងស្តាំនៃចម្លាក់ពោធិសត្វទាំង២អង្គនេះ  ក៏មានរូបចម្លាក់ព្រះពោធិសត្វមានដៃ៤ ជាចម្លាក់អង្គុយពែនភ្នែន ដៃ២ដាក់សម្មាធិ និងដៃពីរទៀតលើកឡើងទៅលើហាក់ដូចជាទ្រអ្វី១? ចម្លាក់នេះមានភាពសិករិចរិល និងពិបាកសន្និដ្ឋានចម្លាក់នេះអាចធ្លាក់មិនទាន់រូប រូបមានកម្ពស់៦៤ស.ម និងទទឹង៦៦ស.ម។

ដោយឡែកសិលាចារឹកចំនួន២ទីតាំងនៃជញ្ជាំងពើង គឺសិលាចារឹកកន្លែងទី១ស្ថិតនៅខាងឆ្វេងនៃច្រកចូលរូងថ្មទី១ ចារចំនួន២បន្ទាត់ជាភាសាខ្មែរ ទំហំ១០សង់ទីម៉ែត្រ និងបណ្តោយប្រមាណ២ម៉ែត្រ សិលាចារឹកមានស្ថានភាពរលប់ដោយសារថ្មមានសភាពពុកផុយ (រូបលេខ២៧)។ សិលាចារឹកនេះមានបង្ហាញពាក្យថាគុហា... អាចជាឈ្មោះនៃទីកន្លែងនេះ។[២] តាមរយៈអក្សរនៃសិលាចារិកនេះអាចចារក្នុងអំឡុងស.វទី១១គ.ស (រូបលេខ២៨)។ ចំពោះសិលាចារឹកកន្លែងទី២ ចារលើផ្ទែកខាងស្តាំនៃរូងថ្មទី១ (រូបលេខ២៩) ជាភាសាខ្មែរដែលស្ថិតនៅស.វទី១១ មានបណ្តោយ៨៧សង់ទីម៉ែត្រ និងកម្ពស់៧៦សង់ទីម៉ែត្រ មានចំនួន៥បន្ទាត់។ សិលាចារឹកនេះ ចារឹកជាភាសាខ្មែរ និងពិបាកក្នុងការអានដោយសារស្ថានភាពថ្ម តែឃើញមានបង្ហាញពាក្យថា ...ភ្នំនេះ....។

រួមសេចក្តីមកទីតាំងពើងតាបស ជាទីតាំងបុរាណស្ថានមួយនៃអ្នកកាន់ពុទ្ធសាសនាមហាយាន យោងតាមរយៈសិលាចារឹកនិងចម្លាក់ប្រហែលជាស្ថិតក្នុងអំឡុង ស.វទី១១ទៅ១២ នៃគ.ស។ ទីតាំងនេះគួរមានទំនាក់ទំនងជាមួយប្រាសាទបាកាណ (ព្រះខាន់កំពង់ស្វាយ) ដែលមានចំងាយប្រមាណ១៥គីឡូម៉ែត្រពីទីនោះ។ រហូតដល់បច្ចុប្បន្ននេះទីតាំងនេះក៏នៅមានអ្នកបួសមកសំណាក់ធម៌ផងដែរ៕

---

[២] យោងប្រសាសន៍លោក ហេងឈុនតេង

អត្ថបទដោយៈ លឹម វណ្ណច័ន្ទ




រូបលេខ១



រូបលេខ២

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ៣-៤



រូបលេខ៥



រូបលេខ២៦



រូបលេខ២៧

អត្ថបទដោយ៖ លឹម វណ្ណចន្ទ



រូបលេខ២៨



រូបលេខ២៩